**ស្ថានទូតអូស្ត្រាលី**
**ភ្នំពេញ**

# សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០១៦

## និស្សិតញូវកូឡុមបូផ្លេននៅកម្ពុជាឆ្នាំ២០១៧

រដ្ឋាភិបាលអូស្ត្រាលី នឹងផ្តល់អាហារូបករណ៍ញូវកូឡុមបូផ្លេនរយៈពេលវែងចំនួនពីរកន្លែងចំពោះ Ms Rachael Dodds និង Ms Jessica Birch-Critchley ដើម្បីស្នាក់នៅ សិក្សា និងធ្វើកម្មសិក្សានៅប្រទេសកម្ពុជានាឆ្នាំ២០១៧។

Ms Rachael Dodds និង Ms Jessica Birch-Critchley នឹងចូលរួមជាមួយនិស្សិតអូស្ត្រាលីថ្នាក់ឧត្តមចំនួន៤៨០នាក់ផ្សេងទៀត ដែលនឹងមកសិក្សានិងធ្វើកម្មសិក្សារយៈពេលខ្លីនៅប្រទេសកម្ពុជានាឆ្នាំ២០១៧។

អ្នកទាំងពីរត្រូវបានទទួលឲ្យសិក្សាដោយសកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា។

ពួកគេនឹងទទួលបាននូវបទពិសោធន៍អនុវត្តជាក់ស្តែងដែលមិនអាចកាត់ថ្លៃបានពីកន្លែងការងារនានានៅកម្ពុជាតាមរយៈកម្មសិក្សា និងការបង្វឹកការ។ Ms Rachael Dodds នឹងចុះកម្មសិក្សានៅអង្គការសិល្បៈរស់កម្ពុជា និងក្រសួងវប្បធម៌និងវិចិត្រសិល្បៈ។

«និស្សិតញូវកូឡុមបូផ្លេននៅកម្ពុជា គឺស្ថិតក្នុងចំណោមពលរដ្ឋអូស្ត្រាលីដ៏ពូកែនិងលេចធ្លោបំផុត ដែលបានបង្ហាញនូវភាពឥតខ្ចោះក្នុងការសិក្សា មានការចូលរួមក្នុងសហគមន៍ និងមានការប្តេជ្ញាចិត្តខ្ពស់ក្នុងការចូលរួមជាមួយប្រជាជនកម្ពុជា។» នេះបើតាមប្រសាសន៍របស់លោកជំទាវឯកអគ្គរាជទូតអូស្ត្រាលី **អេនជេលឡា ខកខីរ៉េន**។

លោកជំទាវបានមានប្រសាសន៍បន្តថា «ខ្ញុំមានសេចក្តីរីករាយដែលកម្មវិធីញូវកូឡុមបូផ្លេន នឹងធ្វើឲចំណងមិត្តភាព ការស្វែងយល់ និងឱកាសរវាងអូស្ត្រាលីនិងកម្ពុជា

កាន់តែរឹងមាំ។ បទពិសោធន៍របស់និស្សិត និងទំនាក់ទំនងមិត្តភាពនិងវិជ្ជាជីវៈដែលនិស្សិតយើងបានបង្កើត នឹងជះឥទ្ធិពលល្អដល់ទំនាក់ទំនងរបស់អូស្ត្រាលីជាមួយកម្ពុជានាពេលច្រើនឆ្នាំខាងមុខ។»

កម្មវិធីញូវកូឡុមបូផ្លេន គឺជាគំនិតផ្តួចផ្តើមមួយរបស់រដ្ឋាភិបាលអូស្ត្រាលីដើម្បីលើកកម្ពស់ការយល់ដឹងនៅក្នុងប្រទេសអូស្ត្រាលី អំពីតំបន់ឥណ្ឌូប៉ាស៊ីភិក តាមរយៈការគាំទ្រដល់និស្សិតអូស្ត្រាលីថ្នាក់ឧត្តមឲ្យមកស្នាក់នៅ សិក្សា និងចុះកម្មសិក្សានៅក្នុងតំបន់។

នៅទូទាំងពិភពលោក រដ្ឋាភិបាលអូស្ត្រាលីបានគាំទ្រដល់និស្សិតអូស្ត្រាលីថ្នាក់ឧត្តមចំនួន ១៧.៥០០ នាក់ឲ្យស្នាក់នៅ សិក្សា និងចុះកម្មសិក្សានៅក្នុងតំបន់ឥណ្ឌូ-ប៉ាស៊ីភិក ក្នុងរយៈពេលបួនឆ្នាំដំបូងបន្ទាប់ពីកម្មវិធីញូវកូឡុមបូផ្លេនត្រូវបានបង្កើត។

**ទំនាក់ទំនងព័ត៌មាន៖** Australian.Embassy.Cambodia@dfat.gov.au ; **023 213 470**